## ៥ សញ្ញាសម្គាល់សម្រាប់ជ័យលាភី ថ្នាក់បរិញ្ញាបត្រ

### ក- រូបសញ្ញា




### ខ- សញ្ញាសម្គាល់សម្រាប់ជ័យលាភីថ្នាក់បរិញ្ញាបត្រ

មានទម្រង់និងអត្ថន័យដូចខាងក្រោម៖

**ខ.១- ទម្រង់**

- មានរូបរាងជាខែលការពារ ពទ្ធជុំវិញដោយក្បាច់ភ្ញីទេសពណ៌មាស ទំហំកម្ពស់២៥ម.ម. និងទទឹង១៧ម.ម.

- ផ្នែកខាងលើមានមកុដរាជតម្កល់នៅពីលើខែលការពារហើយកំពូលមកុដរាជមានពន្លឺរស្មីដែលរះចែងចាំងពណ៌មាសចំនួន២៥។ នៅចំកណ្តាលនៃមកុដរាជមានរូបកងចក្រពណ៌មាស លម្អដោយក្បាច់ផ្កាច័ន្ទពណ៌មាសនៅខាងក្នុង
- ផ្នែកកណ្តាលនៃខែលការពារមានរូបព្រះគណេសពណ៌មាសដែលនៅអមសងខាងរូបព្រះគណេសមានលម្អដោយក្បាច់ផ្កាភ្ញីទេសពណ៌មាស។ រីឯនៅខាងក្រោមព្រះគណេសរំលេចទៅដោយក្រណាត់ បូមានពណ៌ក្រហមខៀវ ហើយក្នុងផ្ទៃបូមានសរសេរពាក្យថា **«បរិញ្ញាបត្រ-BACHELOR'S DEGREE»** ពណ៌មាស។

**ខ.២- អត្ថន័យ**

- **សន្លឹកក្បាច់ភ្ញីទេស** តំណាងឱ្យការរីកចម្រើនលូតលាស់រុងរឿងសម្បូរសប្បាយ
- **ពន្លឺឆព្វណ្ណរង្សី** ស្ថិតនៅពីលើគេ តំណាងឱ្យគំនិត ប្រាជ្ញា ស្មារតី
- **មកុដរាជ** តំណាងឱ្យអំណាចរបស់ព្រះមហាក្សត្រ ដែលផ្តល់ជាម្លប់ដ៏ត្រជាក់ដល់ប្រជានុរាស្ត្រនិងសិទ្ធិអំណាចដល់ស្ថាប័នជាតិ ក្នុងការថែរក្សាការពារសន្តិសុខ សណ្តាប់ធ្នាប់ទូទៅនៅក្នុងព្រះរាជាណាចក្រកម្ពុជា
- **កងចក្រ** តំណាងឱ្យប្រសិទ្ធភាព អំណាច និងសមត្ថកិច្ចក្នុងការអនុវត្តភារកិច្ចថែរក្សាសន្តិសុខនិងសណ្តាប់ធ្នាប់សង្គមទូទាំង២៥រាជធានី ខេត្ត
- **ខែល** តំណាងឱ្យគ្រឿងបិទបាំងការពារគ្រប់មុំទាំងខាងមុខនិងខាងក្រោយ ដែលបង្ហាញលក្ខណៈរឹងមាំនៃកងកម្លាំងនគរបាលជាតិក្នុងការប្រយុទ្ធប្រឆាំង ទប់ស្កាត់រាល់បទល្មើស
- **ព្រះគណេស** ជាអាទិទេពតំណាងឱ្យច្បាប់ បញ្ញា ចំណេះដឹង និងជាអាទិទេពនៃការបំផ្លាញឧបសគ្គ និងអំពើអាក្រក់ទាំងឡាយ។ ក្នុងន័យនេះ ព្រះគណេសតំណាងឱ្យភាពជាអ្នកប្រាជ្ញ ជាបណ្ឌិត ជាអ្នកចេះដឹង អ្នកជួយដល់សត្វទាំងឡាយគ្រប់ទីកន្លែង ដោយប្រកាន់ខ្ជាប់នូវអំពើល្អ សុចរិតភាព

ភាពម៉ឺងម៉ាត់ និងហ្មត់ចត់ ព្រមទាំងបង្កើតឱ្យមានភាពសម្បូររុងរឿង វឌ្ឍនភាព និងវិបុលភាព

- **សន្ទឹកក្បាច់នៅអមព្រះគណេស** តំណាងឱ្យគំនិត ការច្នៃប្រឌិត និងនវានុវត្តន៍
- **ប៊ូពណ៌ខៀវ** និង **ក្រហម** រំលេចវគ្គសិក្សាថ្នាក់ **បរិញ្ញាបត្រ-BACHELOR'S DEGREE** ពណ៌មាសនៅចំកណ្ដាល តំណាងឱ្យសន្តិសុខ សុវត្ថិភាពសង្គម សុខសន្តិភាព សាមគ្គីភាព ភាតរភាព និងនិរន្តរភាព ព្រមទាំងបង្ហាញពីភាពមោះមុត អង់អាចក្លាហាន ការប្ដេជ្ញាចិត្ត ហ៊ានធ្វើពលិកម្ម និងតស៊ូ ប្រយុទ្ធ របស់កងកម្លាំងនគរបាលជាតិក្នុងការបម្រើជាតិនិងប្រជាពលរដ្ឋ
- **ពណ៌មាស** តំណាងឱ្យពន្លឺនៃវិជ្ជាអប់រំបញ្ញា ប្រាជ្ញាស្មារតី ភាពឧត្តុង្គឧត្ដម សេចក្ដីថ្លៃថ្នូរ គុណតម្លៃកងកម្លាំង និងប្រជាពលរដ្ឋទូទាំងប្រទេសកម្ពុជា
- អក្សរ **បរិញ្ញាបត្រ-BACHELOR'S DEGREE** ជាឈ្មោះនៃកម្រិតសញ្ញាបត្រ ដែលបណ្ឌិត្យសភានគរបាលកម្ពុជា ធ្វើការបណ្ដុះបណ្ដាលដល់និស្សិតដែលជាមន្ត្រីនគរបាលជាតិនិងមន្ត្រីពន្ធនាគារនៃក្រសួងមហាផ្ទៃ។

**កំណត់ចំណាំ :**

សញ្ញាសម្គាល់សម្រាប់គោរមងារ **អភិសន្តិបណ្ឌិត សន្តិបណ្ឌិត** និងសញ្ញាសម្គាល់អ្នកសិក្សាជ័យលាភីថ្នាក់ **បណ្ឌិត បរិញ្ញាបត្រជាន់ខ្ពស់** និង **បរិញ្ញាបត្រ** នៃបណ្ឌិត្យសភានគរបាលកម្ពុជា ត្រូវបានប្រើប្រាស់ដោយបំពាក់ជាប់គម្របហោប៉ៅអាវឬបំពាក់ពីលើហោប៉ៅអាវផ្នែកខាងស្ដាំ។